00164496

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 20 / 02 / 2008
ម៉ោង (Time/Heure): 14:50 PM
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

**Declassified to Public**
**06 September 2012**

ជូនលោកសហចៅក្រមស៊ើបអង្កេត៖ **យូ ប៊ុនឡេង**
**Marcel Lemonde**

ផ្ញើជូនពី៖ **នុប សុធនវិចិត្រ, មន្ត្រីគ្រប់គ្រងភស្តុតាង**

តាមរយៈ៖ ក្រាញ់ តូនី, ប្រធានផ្នែកគ្រប់គ្រងតុលាការ

យោង៖ – អនុស្សរណៈផ្ទៃក្នុងរវាងផ្នែកគ្រប់គ្រងតុលាការ និងការិយាល័យសហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០០៧

– លិខិតរបស់ក្រុមមេធាវីការពារក្តីសម្រាប់ កាំង ហ្គិចអៀវ ហៅ ឌុច ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០០៨

កម្មវត្ថុ៖ **ការអង្កេតរបស់ផ្នែកគ្រប់គ្រងតុលាការលើការចូលពិនិត្យសំណុំរឿងលេខ 001/18-07-2007-ECCC-OCIJ**

---

ខ្ញុំសូមរំលឹកថា កាលពីថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០០៨ HELEYN UNAC សមាជិកនៃក្រុមមេធាវីការពារក្តីសម្រាប់ កាំង ហ្គិចអៀវ ហៅ ឌុច បានស្នើសុំមកផ្នែកគ្រប់គ្រងតុលាការដើម្បីផ្ទៀងផ្ទាត់ថា ឯកសាររបស់សំណុំរឿង ដែលមានលើប្រព័ន្ធ Zylab ដូចគ្នាទៅនឹងឯកសាររបស់សំណុំរឿងរឹង។

ដោយហេតុថា HELEYN UNAC មានសិទ្ធក្នុងពិនិត្យឯកសាររបស់សំណុំរឿង គាត់ត្រូវបានអមដំណើរដោយលោក Chea Kosal (មន្ត្រីតុលាការ) ទៅបន្ទប់រក្សាទុកឯកសារ។ ប៉ុន្តែ គួរឱសោកស្តាយ HELEYN UNAC បានធ្វើការសន្និដ្ឋានដូចបានរៀបរាប់ក្នុងលិខិតរបស់ក្រុមមេធាវីការពារក្តីសម្រាប់ កាំង ហ្គិចអៀវ ហៅ ឌុច ចុះ ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០០៨។

ក្នុងន័យនេះ ខ្ញុំសូមបញ្ជាក់ថា ដូចដែលធ្លាប់បានបញ្ជាក់កាលពីពេលកន្លងទៅក្នុង e-mail របស់ខ្ញុំបាទកាលពីថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០៧ ថា ឯកសារទាំងអស់របស់សំណុំរឿងអាចត្រូវចូលពិនិត្យបានតាមរយៈ ប្រព័ន្ធ Zylab។ គ្មានបុគ្គលរូបណាអាចត្រូវបានអនុញ្ញាតឱចូលពិនិត្យឯកសាររបស់សំណុំរឿងរឹងទេ លើកលែងតែក្នុងករណីពិសេសមួយចំនួនប៉ុណ្ណោះ។

ដោយចងចាំថា ផ្នែកគ្រប់គ្រងតុលាការជាភ្នាក់ងាររបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតក្នុងការរក្សាទុកសំណុំរឿងដោយធានាឱបាននូវភាពសម្ងាត់ និងអធិបតេយ្យរបស់ឯកសារក្នុងសំណុំរឿង រាល់ការចូលក្នុងបន្ទប់រក្សាសំណុំរឿងត្រូវបានកំរិត និងអនុញ្ញាតឱតែចំពោះជនណាដែលមានសិទ្ធិពិនិត្យសំណុំរឿងតែប៉ុណ្ណោះ។ រាល់ការចូលក្នុងបន្ទប់នេះត្រូវមានការចុះហត្ថលេខាចូល និងត្រូវអមដំណើរដោយមន្ត្រីផ្នែកបណ្ណសារ។ ...

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 22 / 02 / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

00164497

ឯកសារ A76/I



(001/18-07-2007-ECCC-OCIJ និង 002/19-09-2007-ECCC-OCIJ) ដែលកំពុងលើកឡើង ត្រូវបានរក្សាទុកដាច់ពីគ្នា និងនៅលើថ្មើពីរផ្សេងពីគ្នាផងដែរ។

ដូច្នេះ ក្នុងរយះពេលពិនិត្យសំណុំរឿងដ៏ខ្លីនោះ ជនដែលមានបំណងល្អធម្មតាមិនអាចមានពេលគ្រប់គ្រាន់សម្រាប់ចូលពិនិត្យសំណុំរឿងផ្សេងទៀតដោយងាយនោះទេ។ ទន្ទឹមនឹងនេះ ទោះបីជាក្នុងករណីផ្គាំផ្គង ឬមានចេតនាអាក្រក់ពីជនណាម្នាក់ ផ្នែកគ្រប់គ្រងតុលាការ យល់ថាមានការលំបាក នឹងស្ទើរតែមិនអាចទៅរួចក្នុងការចូលពិនិត្យសំណុំរឿងមួយទៀត ដោយហេតុថាមន្ត្រីតុលាការមាន វត្តមានជាប្រចាំក្នុងពេលពិនិត្យសំណុំរឿងម្តងៗ។

ភ្ជាប់ជាមួយនេះដែរ ដោយហេតុថាសំណុំរឿងអេឡិចត្រូនិចត្រូវបានធ្វើបច្ចុប្បន្នភាពដោយទៀងទាត់ ដើម្បីជៀសវាងនូវការចោទប្រកាន់ដោយគ្មានភស្តុតាង និងបំណងមិនល្អណាមួយ ផ្នែកគ្រប់គ្រងតុលាការសូមស្នើវិធានការបន្ថែមថារាល់ការចូលពិនិត្យសំណុំរឿងរឹង ទោះបីជាជននោះមានសិទ្ធិក្នុងការពិនិត្យសុំណុំរឿងក៏ដោយ ត្រូវមានការអនុញ្ញាតជាលាយល័ក្ខអក្សរជាមុនពីក្រឡាបញ្ជីនៃស្ថាប័នតុលាការដែលពាក់ព័ន្ធ។

សូមលោកសហចៅក្រមស៊ើបអង្កេតមេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

**នុប សុធនវិចិត្រ**
**មន្ត្រីគ្រប់គ្រងភស្តុតាង**